**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៨៨
អក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០
សាលក្រមលេខៈ ០៧៥ 'ណ'
ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១

សាលាដំបូងខេត្តកណ្តាលបានបើកសវនាការនៅសាលាសវនាការ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ,លោកស្រី [redacted] និងលោក [redacted] លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៨៨៨ អ.ក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

១. ឈ្មោះ [redacted] ភាក់ ភេទប្រុស អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ គ្រូបង្រៀន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្តកណ្តាល ប្រពន្ធឈ្មោះ [redacted] ប៊ុនណ្ណា មានកូន ០៤ នាក់ ឪពុកឈ្មោះ [redacted] ង៉ែត (រ) ម្តាយឈ្មោះ [redacted] ធន (រ) ជានីតិជន ទោសពីមុនគ្មាន។

ជាប់ចោទពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារី ភេទប្រុស អាយុ៥៣ឆ្នាំ មុខរបរមន្ត្រីនគរបាលចូលនិវត្តន៍ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកោះកុង។

៣. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភា ភេទប្រុស អាយុ៤៨ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិសន្លុង ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

**អង្គហេតុនៃរឿងមានដូចតទៅៈ**

កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ២១ និង ០០នាទី ស្ថិតនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឈ្មោះ [redacted] ភា និងប្រពន្ធកូន បានដើរត្រឡប់មកពីហូបបាយផ្ទះម្តាយឈ្មោះ [redacted] ង៉ែត មកដល់ចំណុចផ្ទះរបស់ឈ្មោះ [redacted] ភាក់ ស្រាប់តែឈ្មោះ [redacted] ភាក់ ត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] ភា បានយកដំបងវែងវាយទៅលើឈ្មោះ [redacted] ភា តែ

មិនត្រូវ។ ភ្លាមនោះឈ្មោះ [redacted] ភា បានសួរថា អាភាក់ហ្អែងគប់ដុំថ្មអ៊ីចឹងបើត្រូវក្បាលមិនងាប់ហើយ ឈ្មោះ [redacted] ភាក់ បានស្រែកថា ពួកហ្អែងឡូឡាររក អញដេកមិនបានពួកហ្អែងលួចដីអញ។ បន្ទាប់មកអ្នកទាំងពីរក៏មានទំនាស់គ្នា ហើយឈ្មោះ [redacted] សារី ត្រូវជាបងថ្លៃបានដើរចេញមកឃាត់កុំឲ្យឈ្លោះគ្នា ស្រាប់តែឈ្មោះ [redacted] ភាក់ បានស្ទុះទៅយកដុំឥដ្ឋប្រហោងគប់ត្រូវស្មាខាងស្តាំរបស់ឈ្មោះ [redacted] សារី មួយដុំឥដ្ឋ បណ្តាលឲ្យមានរបួសហើមជាំ។ ឈ្មោះ [redacted] ភា បានស្រែកឲ្យឈ្មោះ [redacted] ភាក់ រត់ចូលផ្ទះទាញយកដំបងឬស្សី និងកាំបិតខ្វែវដេញកាប់ឈ្មោះ [redacted] ភា ពេលនោះឈ្មោះ [redacted] ភា បានរត់ចូលផ្ទះរបស់ខ្លួនបិទទ្វារ ត្រូវបានឈ្មោះ [redacted] ភាក់ យកដំបងឬស្សីវាយទ្វារបណ្តាលឲ្យកំពិតជាច្រើនកន្លែងតែម្តង។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ៨២០ ដកជរជ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ២២២៣ ជរ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

-អានចម្លើយជនត្រូវចោទឈ្មោះ [redacted] ភាក់ បានឆ្លើយថាៈ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ វេលាម៉ោង ៩ យប់ ខ្លួនបានជិះម៉ូតូ ម្នាក់ឯងមកពីចិញ្ចឹមទា ពេលមកដល់ផ្ទះឃើញមនុស្សជាច្រើនកំពុងអង្គុយផឹកស្រានៅក្រោមផ្ទះឪពុកខ្លួនឈ្មោះ [redacted] ង៉ែត ហើយនិយាយ និងឡូឡាយ៉ាងខ្លាំង តែខ្លួនមិនបានចូលរួម នឹងនិយាយអ្វីទេ ហើយខ្លួនក៏ទៅដេកអង្រឹងនៅមុខផ្ទះ។ ដល់ម៉ោង ១០ យប់ថ្ងៃដដែល ដោយពួកនេះឡូឡាលឺខ្លាំង ខ្លួនយកដំបងឬស្សី គូសជញ្ជាំងផ្ទះ ជាសញ្ញាកុំឲ្យអ្នកផឹកស៊ីនោះ ស្ងប់ស្ងាត់ ប៉ុន្តែពីផ្ទះឪពុកខ្លួនមកនៅចំហៀងខាងលិចផ្ទះខ្លួន ហើយឈ្មោះ [redacted] ភា ស្រែកថា ហ្អែងឈ្លើយម៉េះ មើលអញវ៉ៃ ហ្អែងម្តងមើលអញកុំយូរហើយ ពេលនោះខ្លួនបានដើរទៅរកឈ្មោះ ណង់ ភា ស្រាប់តែឈ្មោះ [redacted] ភា ស្ទុះមកវាយខ្លួនក៏បានគេចផុតហើយក៏រុញឈ្មោះ [redacted] ភា ដួលទៅលើដី ពេលនោះឈ្មោះ ខាន់ ចូលមកឃាត់ខ្លួន បន្ទាប់មកឈ្មោះ [redacted] ភា ស្ទុះមកវាយខ្លួនម្តងទៀតតែត្រូវខ្លួនរុញដួលម្តងទៀត ពេលនោះឈ្មោះ សារី និយាយថា អញបាញអោយងាប់ បន្តិចក្រោយមកលឺសួរផ្ទុះអាវុធចំនួន២ គ្រាប់ហើយ ឈ្មោះ [redacted] សារី ដើរចូលមកជិតខ្លួនយកកាំភ្លើងខ្លី មិនស្គាល់ មកភ្ជុងខ្លួន ឃើញដូចនោះខ្លួនបានស្រែកថា បាញមកអញចង់ងាប់ តែឈ្មោះ ខាន់ បានចូលទៅឃាត់ឈ្មោះ [redacted] សារី បណ្តាលឲ្យជ្រុះកាំភ្លើងទៅលើដី ហើយដាល់ខ្លួនមួយដៃធ្វើឲ្យខ្លួនដួលទៅលើដីទើបឈ្មោះណង់ ភា ស្ទុះមកវាយត្រូវមាត់ខ្លួនជាច្រើន បណ្តាលឲ្យមានរបួស ហើយក៏មានមនុស្សចូលមកឃាត់ទើប ខ្លួនទៅផ្ទះវិញទៅ។

-អានចម្លើយជនរងគ្រោះឈ្មោះ [redacted] ភា បានឆ្លើយថាៈ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៧ យប់ ខ្លួនបានទៅហូបបាយនៅផ្ទះឪពុកក្មេកខ្លួន ហើយឈ្មោះ [redacted] ង៉ែត និងឈ្មោះ [redacted] សេរី ជាបងថ្លៃខ្លួនបានផឹកស្រាតែមានច្រៀងរាំអ្វីនោះទេ ។ដល់វេលាម៉ោង ០៩ និង៣០ នាទីខ្លួននិងប្រពន្ធកូនខ្លួនជាមួយឈ្មោះ [redacted] ធី និងឈ្មោះ ខាន់បាន ដើរមកផ្ទះខ្លួនវិញពេលដើរមកដល់ចំហៀងផ្ទះឈ្មោះ [redacted] ភាក់ មានបើកភ្លើងអំពូលម៉ែត្រភ្លឺច្បាស់ស្រាប់តែឃើញឈ្មោះ [redacted] ភាក់ បានយកដុំឥដ្ឋ គប់សំដៅមកខ្លួនបានតែមិនត្រូវពេលនោះខ្លួនសួរថាឯងគប់និងដុំឥដ្ឋអញ្ចឹងបើត្រូវក្បាលងាប់ហើយ [redacted] ភាក់ ក៏ស្រែកថាពួកឯងឡូឡា ថ្លង់ណាស់រកដេកមិនបានពួកឯងលួចអី ខ្លួននិយាយថាគ្មានអ្នកណាលួចរបស់ហ្អែងទេស្រាបពេលនោះឈ្មោះ

[redacted] សេរី បានចូលមកឃាត់ស្រាប់តែឈ្មោះ [redacted] ភាក់ ស្ទុះទៅយកដុំឥដ្ឋខាងមុខផ្ទះខ្លួនគប់មកត្រូវស្មារឈ្មោះ [redacted] សេរី បន្ទាប់មកខ្លួនបានសួរថាហើយម៉េចគប់គេចឹងស្រាប់តែឈ្មោះ [redacted] ភាក់ ស្ទុះមកវាយរូបខ្លួនហើយ ប្រតាយ ប្រតប់ គ្នាទៅវិញទៅមកបន្តិចក្រោយមកឈ្មោះ [redacted] សេរី និងឈ្មោះ ខាន់ បានចូលមកឃាត់ហើយឈ្មោះ [redacted] ភាក់ បានរត់ចូលផ្ទះខ្លួនយកដំបងឫស្សី និងកាំបិតសំដៅមករកខ្លួនឃើញដូចនេះខ្លួនបានរត់ចូលផ្ទះហើយខ្លួនបិទទ្វាចាក់គន្លឹះពីក្នុងជាប់ទើបឈ្មោះ [redacted] ភាក់ យកដំបងឫស្សីវាយជញ្ជាំង និងទ្វារផ្ទះដែលធ្វើពីស័ង្កសីជាច្រើនដំបងឮផាំងផាំងទើបឈ្មោះ [redacted] សេរី និងឈ្មោះ ខាន់ ចូលមកឃាត់ឈ្មោះ [redacted] ភាក់ ដោយអ្នកទាំងពីរមិនមានកាន់អ្វីទេហើយក៏គ្មានបាញ់អ្វីដែលគឺមានតែគោះទ្វាផ្ទះរបស់ខ្លួន តាំងពីពេលហូបបាយមកមានតែការប្រតាយប្រតប់គ្នាឈ្មោះ [redacted] សេរី មិនមានកាំភ្លើងទេ។

-អានចម្លើយជនរងគ្រោះឈ្មោះ [redacted] សារី បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ យប់ ខ្លួនបានលឺសំលេងឈ្មោះ [redacted] ភា ឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ [redacted] ភាក់ នៅម្តុំផ្ទះឈ្មោះ [redacted] ភាក់ នេះពេលលឺដូចនេះ ខ្លួនបានដើរទៅសួរឈ្មោះ [redacted] ផា និងឈ្មោះ [redacted] ភាក់ ទាស់គ្នារឿងអ្វី សុទ្ធតែបងប្អូនឯងទេ ពេលនោះឈ្មោះ [redacted] ភាក់ ស្ទុះយកដុំឥដ្ឋគុបក្បាលខ្លួន តែមិនត្រូវមកត្រូវចំស្មា ចំហៀងខាងស្តាំមួយ ដុំឥដ្ឋបណ្តាលឲ្យមានរបួសហើមជាំ ហើយឈ្មោះ [redacted] ភាក់ បានស្ទុះទៅវាយឈ្មោះ [redacted] ភា ប្រតាយប្រតប់ គ្នា ខ្លួនក៏បានចូលទៅឃាត់ បន្ទាប់មកឈ្មោះ [redacted] ភាក់ បានរត់ទៅផ្ទះយកដំបងឫស្សី និងកាំបិត មកដេញវាយឈ្មោះ [redacted] ភា ក្រោយមកឈ្មោះ [redacted] ភា បានរត់ចូលផ្ទះហើយ ឈ្មោះ [redacted] ភាក់ បានវាយទ្វារផ្ទះក្រោយមកនគរបាលក៏បានមកដល់ ជួយធ្វើអន្តរាគមន៍ ហើយខ្លួនមិនមានអាវុធប្រើទេ។

-អានចម្លើយសាក្សីឈ្មោះ [redacted] ខាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែ សីហា ឆ្នាំ ២០២០ វេលាម៉ោង០៦:៣០ល្ងាចឈ្មោះ សៀង បានទៅទិញម្ហូបយកមកហូបបាយនៅផ្ទះរបស់ឈ្មោះ [redacted] ដែលត្រូវជាជីតាខាងប្រពន្ធនិងបានហៅខ្លួន និងឈ្មោះ [redacted] ភា និងប្រពន្ធឈ្មោះរ៉ា និងប្រពន្ធឈ្មោះ [redacted] ធី ពេលកំពុងតែហូបបាយក៏និយាយគ្នាយកស្រាថ្នាំមកផឹកអស់ចំនួន ២ លីត្រដល់ម៉ោង ០៩:១០ ខ្លួននិងប្រពន្ធនិងមនុស្សផ្សេងទៀតក៏បានលាគ្នាមកផ្ទះដោយឈរនិយាយគ្នានៅមុខផ្ទះឈ្មោះ [redacted] ស្រាប់តែឮសំឡេងចេញពីផ្ទះរបស់ឈ្មោះ [redacted] ភាក់ ត្រូវជាកូនរបស់ឈ្មោះ [redacted] ឮដូច្នេះខ្លួនបានរួមជាមួយឈ្មោះ [redacted] ភា ឈ្មោះរ៉ា បានដើរទៅមើលពេលដើរទៅដល់ទន្ទឹមផ្ទះឈ្មោះ [redacted] ភាក់ ចំហៀងផ្ទះខាងលិចស្រាប់តែឈ្មោះ [redacted] ភាក់ យកដុំឥដ្ឋគប់មកត្រូវស្មាខាងស្តាំរបស់ឈ្មោះរ៉ា ប៉ុន្តែឈ្មោះរ៉ា ពុំមាននិយាយអ្វីទេហើយក៏ពុំមានកាន់ អ្វីដែរពេលនោះឈ្មោះ [redacted] ភាដែលត្រូវជាបងថ្លៃរបស់ឈ្មោះ [redacted] ភាក់ បានស្រែកប្រាប់ឈ្មោះ [redacted] ភាក់ ថាហើយល្មមៗបានហើយស្រាប់តែឈ្មោះ ភាក់ ស្ទុះមកវាយប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ភា ឃើញដូច្នេះខ្លួន និងឈ្មោះ រ៉ា បានចូលឃាត់ពេលចូលទៅដល់ឃើញឈ្មោះ [redacted] ភាក់ មានរបួសឈាមមាត់មួយកន្លែងហើយឈ្មោះ [redacted] ភា បានរត់ចូលទៅផ្ទះគាត់ភ្លាមនោះឈ្មោះ ង៉ែត ភាក់ បានចូលមកយកដំបងឫស្សីពីមុខផ្ទះខ្លួន ដេញតាមវាយឈ្មោះ [redacted] ភា តែពេលនោះឈ្មោះ [redacted] ភា បានចូលទៅក្នុងផ្ទះហើយបិទទ្វារទើបឈ្មោះ [redacted] ភាក់ យកដំបងឫស្សីវាយទ្វារផ្ទះរបស់ឈ្មោះ [redacted] ភា ហើយដាក់ជាច្រើនដំបងបណ្តាលឱ្យកំពិតជាច្រើនកន្លែងបន្ទាប់មក

Scanned with CamScanner

ខ្លួន និងមនុស្សជាច្រើននាក់បានចូលទៅចាប់ឃាត់ឈ្មោះ [redacted] ភាក់ នាំទៅផ្ទះតែឈ្មោះ [redacted] ភាក់ នៅតែជេរក្រុមគ្រួសារឈ្មោះ រ៉ា ពុំមានតបតអ្វីទេហើយឈ្មោះរ៉ា ពុំមានកាន់កាំភ្លើងទេនិងមិនបានវាយ ប៉ះពាល់លើឈ្មោះ ភាក់ នោះទេបន្តិចក្រោយមកសមត្ថកិច្ចនគរបាលប៉ុស្តិ៍បានចុះទៅដល់ស្រាប់តែឈ្មោះភាក់ គេចខ្លួនបាត់ក្នុងហេតុការណ៍នេះក៏មានអ្នកណាកាន់កាំភ្លើងឬមានស្នូរផ្ទុះអាវុធដែល។

-អានចម្លើយសាក្សីឈ្មោះ [redacted] ង៉ែត បានឆ្លើយថា: កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង០៥ ល្ងាច ខ្លួនបានហូបស្រាគ្រាំទំពាំងបាយជូនៅកញ្ចុះជំហៀងខាងត្បូងផ្ទះខ្លួនរហូតដល់ម៉ោង ០៧:០០ នាទីយប់ខ្លួនបានចូលដេកក្នុងផ្ទះម្នាក់ឯងចំណែកកូនចៅគេនៅហូបស្របន្តដល់ម៉ោង ០៩:០០ ពេលខ្លួនកំពុងដេកក្នុងផ្ទះស្រាប់តែឮសំឡេងមនុស្សប្រកែកគ្នាពីថ្នល់កៅស៊ូនៅចំហៀងផ្ទះឮដូចនោះ ខ្លួនក៏ចេញទៅមើលឃើញកូននិងចៅកំពុងតែឈរឈ្លោះប្រកែកជាមួយកូនប្រុសខ្លួនឈ្មោះ [redacted] ភាក់ ពេលនោះខ្លួនសួរថាមានរឿងអីទើបកូនឈ្មោះ [redacted] ភាឆ្លើយថាបងៗ និងក្មួយខ្លួន និងប្រពន្ធខ្លួនមកឈរលើរផ្លូវស្រាប់តែ [redacted] ភាក់ យកដុំឥដ្ឋគប់ត្រូវបងថ្លៃឈ្មោះ [redacted] សារី មួយដុំឥដ្ឋត្រូវស្មាខាងស្តាំពេលនោះកូនខ្លួនឈ្មោះ [redacted] ភាក់ បានហៅរមករកពួកកូនខ្លួនផ្សេងទៀតហើយស្រែកថា ឯងខ្លាំងវាយជាមួយអញហើយលឺដូចនេះខ្លួនក៏និយាយឯងកុំមានគំនិតអាក្រក់រួចខ្លួនប្រាប់ទៅចៅប្រុសខ្លួនឈ្មោះ [redacted] ចិត្រា ចាំកូនខ្លួនឈ្មោះ [redacted] ភាក់ចូលក្នុងផ្ទះ ហើយចៅខ្លួនបានចាប់កូនប្រុសចូលក្នុងរបងផ្ទះកូនខ្លួនហើយទាញទ្វាររបងបិតរួចកូនប្រុសខ្លួននោះបានទាញទ្វាររបងចេញមកជេររករឿងកូនចៅខ្លួនទៀតបើបន្តិចទៅសមត្ថកិច្ចនគរបាលចុះមកអន្តរាគមន៍ទើបកូនខ្លួនឈ្មោះ [redacted] ភាក់ ដើរចូលក្នុងផ្ទះវិញរួចរត់គេចខ្លួនបាត់បញ្ជាក់ពេលនោះខ្លួនដេកក្នុងផ្ទះទើបមិនបានដឹងថាអ្នកណាបាញ់។

-អានចម្លើយសាក្សីឈ្មោះ [redacted] យឿត បានឆ្លើយថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២០ វេលាម៉ោង ០៩យប់ពេលខ្លួនកំពុងនៅក្នុងផ្ទះស្រាប់តែលឺសំឡេងស្រែកដូចជាសំឡេងគេវាយដែកចេញពីទិសខាងលិចលឺដូចនេះក៏ដើរចេញទៅមើលដល់ផ្ទះ ឈ្មោះ [redacted] ភា ពេលនោះឈ្មោះ [redacted] ភាក់បានយកដំបងដេញវាយឈ្មោះ [redacted] ឡានៅមុខផ្ទះឈ្មោះ [redacted] ភាដូចនេះឈ្មោះ [redacted] ភា បានរត់ទៅឃាត់ស្រាប់តែឈ្មោះ [redacted] ភាក់ ច្រានឈ្មោះ [redacted] ភា ដួលទៅលើដីភ្លាមនោះឈ្មោះ [redacted] កាលីន និងឈ្មោះ [redacted] ចិត្រ្តា បានចូលទៅចាប់ចេញ និងទាញចូលទៅដីឡូត៍របស់ខ្លួននៅទល់មុខផ្ទះរបស់ឈ្មោះ [redacted] ភា ដោយពេលនោះមិនមានអ្នកណាប្រើហិង្សាដាក់ឈ្មោះ [redacted] ភាក់ ទេពេលនោះសមត្ថកិច្ចបានមកដល់ឈ្មោះ [redacted] ភាក់ បានរត់គេចខ្លួនបាត់។បញ្ជាក់ពេលនោះខ្លួនបានឃើញ [redacted] ភាក់ឈរកាន់ដំបងនៅមុខផ្ទះហើយពុំមាននរណាម្នាក់កាន់កាំភ្លើងដែលដូចនេះហើយច្បាស់ជា [redacted] ភាក់យកដំបងទៅវាយទ្វាផ្ទះរបស់ណាង់ភា។

-អានចម្លើយរបស់សាក្សីឈ្មោះ [redacted] ភារ៉ា បានឆ្លើយថា: កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ ម៉ោង០៩យប់ខ្លួន និងប្រពន្ធខ្លួនកំពុងដេកនៅផ្ទះក៏បានលឺគេឈ្លោះគ្នានៅមុខផ្ទះឈ្មោះ [redacted] ភា ហើយខ្លួនបានឃើញឈ្មោះ [redacted] ភាក់ ឈរកាន់ដំបងវាយជញ្ជាំងផ្ទះឈ្មោះ [redacted] ភា លឺគ្រាំងៗហើយក៏បានឃើញឈ្មោះ [redacted] ហៅ រ៉ា បានចូលមកឃាត់ឈ្មោះ [redacted] ភាក់ដោយមិនបានឃើញសារីបានកាន់អាវុធឬវត្ថុអ្វីទេ ហើយក៏មិនមានការផ្ទុះអាវុធដែល ។ហើយឈ្មោះ [redacted] ភាក់ ក៏បានដើរចូលផ្ទះវិញដោយមិនមានរបួសស្នាមអ្វីដែល ។ វេលាម៉ោង ១០ យប់ឈ្មោះ [redacted]

Scanned with CamScanner

ភាក់ ទូរស័ព្ទមកឲ្យយកការបូបលុយនៅមុខផ្ទះមកទុកខ្លួនក៏សួរថាពូជិះអ្វីមកឈ្មោះ [redacted] ភាក់ក៏ឆ្លើយថាពូជិះម៉ូតូមករឿងហេតុយ៉ាងណាខ្លួនមិនបានដឹងទេ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] ភាក់ ជាប់ចោទពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាលខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារសិទ្ធិឱ្យជងរងគ្រោះធ្វើសេចក្តីសន្និដ្ឋានថា៖ ជនល្មើសមានចេតនាវាយទៅលើជនរងគ្រោះមិនប្រាកដមែន និងធ្វើឱ្យខូតខាតផ្ទះជាច្រើនកន្លែង រួចសុំផ្តន្ទាទោសជនល្មើសតាមច្បាប់។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ

ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>យល់ឃើញថា៖</u>**

**ក.អំពីពិរុទ្ធភាព**

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២១៩០ ជរ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ បានបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភាក់ ជាប់ចោទពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាលខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២-តាមចម្លើយជនត្រូវចោទឈ្មោះ [redacted] ភាក់ បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ៩ យប់ ខ្លួនបានជិះម៉ូតូ ម្នាក់ឯងមកពីចិញ្ចឹមទា ពេលមកដល់ផ្ទះឃើញមនុស្សជាច្រើនកំពុងអង្គុយផឹកស្រានៅក្រោមផ្ទះឪពុកខ្លួនឈ្មោះ [redacted] ង៉ែត ហើយនិយាយ និងឡូឡាយ៉ាងខ្លាំង តែខ្លួនមិនបានចូលរួម នឹងនិយាយអ្វីទេ ហើយខ្លួនក៏ទៅដេកអង្រឹងនៅមុខផ្ទះ។ ដល់ម៉ោង ១០ យប់ថ្ងៃដដែល ដោយពួកនេះឡូឡាលឺខ្លាំង ខ្លួនយកដំបងឫស្សី គួសជញ្ជាំងផ្ទះ ជាសញ្ញាកុំឲ្យអ្នកផឹកស៊ីនោះ ស្ងប់ស្ងាត់ ប៉ុន្តែពីផ្ទះឪពុកខ្លួនមកនៅចំហៀងខាងលិចផ្ទះខ្លួន ហើយឈ្មោះ [redacted] ភា ស្រែកថា ហ្អែងឈ្លើយម៉េះ មើលអញវ៉ៃ ហ្អែងម្តងមើលអញកុំយូរ ហើយ ពេលនោះខ្លួនបានដើរទៅរកឈ្មោះ [redacted] ភា ស្រាប់តែឈ្មោះ [redacted] ភា ស្ទុះមកវាយខ្លួនក៏បានគេចផុតហើយក៏រុញឈ្មោះ [redacted] ភា ដួលទៅលើដី ពេលនោះឈ្មោះ ខាន់ ចូលមកឃាត់ខ្លួន បន្ទាប់មកឈ្មោះ [redacted] ភា ស្ទុះមកវាយខ្លួនម្តងទៀតតែត្រូវខ្លួនរុញដួលម្តងទៀត ពេលនោះឈ្មោះ សារី និយាយថា អញបាញអោយងាប់ បន្តិចក្រោយមកលឺសូរផ្ទុះអាវុធចំនួន២ គ្រាប់ ហើយ ឈ្មោះ [redacted] សារី ដើរចូលមកជិតខ្លួនយកកាំភ្លើងខ្លី មិនស្គាល់ មកភ្ជុងខ្លួន ឃើញដូចនោះខ្លួនបានស្រែកថា បាញមកអញចង់ងាប់ តែឈ្មោះ ខាន់ បានចូលទៅឃាត់ឈ្មោះ [redacted] សារី បណ្តាលឲ្យជ្រុះកាំភ្លើងទៅលើដី ហើយដាល់ខ្លួនមួយដៃធ្វើឲ្យខ្លួនដួលទៅលើដីទើបឈ្មោះ [redacted] ភា ស្ទុះមកវាយត្រូវមាត់ខ្លួនជាច្រើន បណ្តាលឲ្យមានរបួស ហើយក៏មានមនុស្សចូលមកឃាត់ទើប ខ្លួនទៅផ្ទះវិញទៅ។

៣-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ភា បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៧ យប់ ខ្លួនបានទៅហូបបាយនៅផ្ទះឪពុកក្មេកខ្លួន ហើយឈ្មោះ [redacted] ង៉ែត និងឈ្មោះ [redacted] សេរី ជាបងថ្លៃខ្លួនបានផឹកស្រាតែមានច្រៀងរាំអ្វីនោះទេ ។ដល់វេលាម៉ោង

០៩ និង៣០ នាទីខ្លួននិងប្រពន្ធកូនខ្លួនជាមួយឈ្មោះ [redacted]ធី និងឈ្មោះ ខាន់ បានដើរមកផ្ទះខ្លួនវិញពេលដើរមកដល់ចំហៀងផ្ទះឈ្មោះ [redacted] ភាក់ មានបើកភ្លើងអំពូលម៉ែត្រភ្លឺច្បាស់ស្រាប់តែឃើញឈ្មោះ [redacted] ភាក់ បានយកដុំឥដ្ឋ គប់សំដៅមកខ្លួនបានតែមិនត្រូវពេលនោះខ្លួនសួរថាឯងគប់និងដុំឥដ្ឋអញ្ចឹងបើត្រូវក្បាលងាប់ហើយ [redacted] ភាក់ ក៏ស្រែកថាពួកឯងឡូឡា ថ្លង់ណាស់រកដេកមិនបានពួកឯងលួចអី ខ្លួននិយាយថាគ្មានអ្នកណាលួចរបស់ហ្អែងទេស្របពេលនោះឈ្មោះ [redacted] សេរី បានចូលមកឃាត់ស្រាប់តែឈ្មោះ [redacted] ភាក់ ស្ទុះទៅយកដុំឥដ្ឋខាងមុខផ្ទះខ្លួនគប់មកត្រូវស្មារឈ្មោះ [redacted] សេរី បន្ទាប់មកខ្លួនបានសួរថាហើយម៉េចគប់គេចឹងស្រាប់តែឈ្មោះ [redacted] ភាក់ ស្ទុះមកវាយរូបខ្លួនហើយ ប្រតាយ ប្រតប់ គ្នាទៅវិញទៅមកបន្តិចក្រោយមកឈ្មោះ [redacted]សេរី និងឈ្មោះ ខាន់ បានចូលមកឃាត់ហើយឈ្មោះ [redacted] ភាក់ បានរត់ចូលផ្ទះខ្លួន យកដំបងឫស្សីនិងកាំបិតសំដៅមករកខ្លួនឃើញដូចនេះខ្លួនបានរត់ចូលផ្ទះហើយខ្លួនបិទទ្វាចាក់គន្លឹះពីក្នុងជាប់ទើបឈ្មោះ [redacted] ភាក់ យកដំបងឫស្សីវាយជញ្ជាំងនិងទ្វារផ្ទះដែលធ្វើពីស័ង្កសីជាច្រើនដំបងឮផាំងផាំងទើបឈ្មោះ [redacted] សេរី និងឈ្មោះ ខាន់ ចូលមកឃាត់ឈ្មោះ [redacted] ភាក់ ដោយអ្នកទាំងពីរមិនមានកាន់អ្វីទេហើយក៏គ្មានបាញ់អ្វីដែលគឺមានតែគោះទ្វាផ្ទះរបស់ខ្លួន តាំងពីពេលហូបបាយមកមានតែការប្រតាយប្រតប់គ្នាឈ្មោះ [redacted] សេរី មិនមានកាំភ្លើងទេ។

៤-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] សារី បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ យប់ ខ្លួនបានលឺសំលេងឈ្មោះ [redacted] ភា ឈ្លោះប្រកែកពាក្យសំដីជាមួយឈ្មោះ [redacted] ភាក់ នៅមុំផ្ទះឈ្មោះ [redacted] ភាក់ នេះពេលលឺដូចនេះ ខ្លួនបានដើរទៅសួរឈ្មោះ [redacted] ផា និងឈ្មោះ [redacted] ភាក់ ទាស់គ្នារឿងអ្វី សុទ្ធតែបងប្អូនឯងទេ ពេលនោះឈ្មោះ [redacted] ភាក់ ស្ទុះយកដុំឥដ្ឋគប់ក្បាលខ្លួន តែមិនត្រូវមកត្រូវចំស្មា ចំហៀងខាងស្តាំមួយ ដុំឥដ្ឋបណ្តាលឲ្យមានរបួសហើមជាំ ហើយឈ្មោះ [redacted] ភាក់ បានស្ទុះទៅវាយឈ្មោះ [redacted] ភា ប្រតាយប្រតប់ គ្នា ខ្លួនក៏បានចូលទៅឃាត់ បន្ទាប់មកឈ្មោះ [redacted]ភាក់ បានរត់ទៅផ្ទះយកដំបងឫស្សី និងកាំបិត មកដេញវាយឈ្មោះ [redacted] ភា ក្រោយមកឈ្មោះ [redacted] ភា បានរត់ចូលផ្ទះហើយ ឈ្មោះ [redacted]ភាក់ បានវាយទ្វារផ្ទះក្រោយមកនគរបាលក៏បានមកដល់ ជួយធ្វើអន្តរាគមន៍ ហើយខ្លួនមិនមានអាវុធប្រើទេ។

៥-តាមចម្លើយសាក្សីឈ្មោះ [redacted] ខាន់ បានឆ្លើយថា៖ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ វេលាម៉ោង០៦:៣០ល្ងាចឈ្មោះ សៀង បានទៅទិញម្ហូបយកមកហូបបាយនៅផ្ទះរបស់ឈ្មោះ [redacted] ដែលត្រូវជាជីតាខាងប្រពន្ធនិងបានហៅខ្លួន និងឈ្មោះ [redacted] ភា និងប្រពន្ធឈ្មោះរ៉ា និងប្រពន្ធឈ្មោះ [redacted]ធី ពេលកំពុងតែហូបបាយក៏និយាយគ្នាយកស្រាថ្នាំមកផឹកអស់ចំនួន ២ លីត្រ ដល់ម៉ោង ០៩:១០ ខ្លួននិងប្រពន្ធនិងមនុស្សផ្សេងទៀតក៏បានលាគ្នាមកផ្ទះដោយឈរនិយាយគ្នានៅមុខផ្ទះឈ្មោះ ង៉ែត ស្រាប់តែឮសំឡេងចេញពីផ្ទះរបស់ឈ្មោះ [redacted] ភាក់ ត្រូវជាកូនរបស់ឈ្មោះង៉ែត ឮដូច្នេះខ្លួនបានរួមជាមួយឈ្មោះ [redacted] ភា ឈ្មោះរ៉ា បានដើរទៅមើលពេលដើរទៅដល់ទន្ទឹមផ្ទះឈ្មោះ [redacted] ភាក់ ចំហៀងផ្ទះខាងលិចស្រាប់តែឈ្មោះ [redacted] ភាក់ យកដុំឥដ្ឋគប់មកត្រូវស្មាខាងស្តាំរបស់ឈ្មោះរ៉ា ប៉ុន្តែឈ្មោះរ៉ា ពុំមាននិយាយអ្វីទេហើយក៏ពុំមានកាន់ អ្វីដែរពេលនោះឈ្មោះ [redacted] ភាដែលត្រូវជាបងថ្លៃរបស់ឈ្មោះ [redacted]ភាក់ បានស្រែកប្រាប់ឈ្មោះ [redacted] ភាក់ ថាហើយល្មមៗបានហើយស្រាប់តែឈ្មោះ ភាក់ ស្ទុះមកវាយប្រតាយប្រតប់ជាមួយឈ្មោះ [redacted]

ភា ឃើញផ្ទះខ្លួន និងឈ្មោះរ៉ា បានចូលឃាត់ពេលចូលទៅដល់ឃើញឈ្មោះ [redacted] ភាក់ មានរបូសឈាមមាត់មួយកន្លែងហើយឈ្មោះ [redacted] ភា បានរត់ចូលទៅផ្ទះគាត់ភ្លាមនោះឈ្មោះ [redacted] ភាក់ បានចូលមកយកដំបងឫស្សីពីមុខផ្ទះខ្លួន ដេញតាមវាយឈ្មោះ [redacted] ភា តែពេលនោះឈ្មោះ [redacted] ភា បានចូលទៅក្នុងផ្ទះហើយបិទទ្វារទើបឈ្មោះ [redacted] ភាក់ យកដំបងឫស្សីវាយទ្វារផ្ទះរបស់ឈ្មោះ [redacted] ភា ហើយដាក់ជាច្រើនដំបងបណ្តាលឱ្យកំពិតជាច្រើនកន្លែងបន្ទាប់មកខ្លួននិងមនុស្សជាច្រើននាក់បានចូលទៅចាប់ឃាត់ឈ្មោះ [redacted] ភាក់ នាំទៅផ្ទះតែឈ្មោះ [redacted] ភាក់នៅតែជេរក្រុមគ្រួសារឈ្មោះ រ៉ា ពុំមានតបតអ្វីទេហើយឈ្មោះ រ៉ា ពុំមានកាន់កាំភ្លើងទេ និងមិនបានវាយ ប៉ះពាល់លើឈ្មោះ ភាក់ នោះទេបន្តិចក្រោយមកសមត្ថកិច្ចនគរបាលប៉ុស្តិ៍បានចុះទៅដល់ស្រាប់តែឈ្មោះភាក់ គេចខ្លួនបាត់ក្នុងហេតុការណ៍នេះក៏មានអ្នកណាកាន់កាំភ្លើងឬមានស្នូរផ្ទុះអាវុធដែល។

៦-តាមចម្លើយសាក្សីឈ្មោះ [redacted] ង៉ែត បានឆ្លើយថាៈកាលពីថ្ងៃទី១៣ខែសីហា ឆ្នាំ២០២០ វេលាម៉ោង០៥ ល្ងាច ខ្លួនបានហូបស្រាត្រាំទំពាំងបាយជូនៅកញ្ចុះជំហៀងខាងត្បូងផ្ទះខ្លួនរហូតដល់ម៉ោង០៧:០០ នាទីយប់ខ្លួនបានចូលដេកក្នុងផ្ទះម្នាក់ឯងចំណែកកូនចៅគេនៅហូបស្រាបន្តដល់ម៉ោង ០៩:០០ ពេលខ្លួនកំពុងដេកក្នុងផ្ទះស្រាប់តែឮសំឡេងមនុស្សប្រកែកគ្នាពីថ្នល់កៅស៊ូនៅចំហៀងផ្ទះឮដូចនោះ ខ្លួនក៏ចេញទៅមើលឃើញកូន និងចៅកំពុងតែឈរឈ្លោះ ប្រកែកជាមួយកូនប្រុសខ្លួនឈ្មោះ [redacted] ភាក់ ពេលនោះខ្លួនសួរថាមានរឿងអីទើបកូនឈ្មោះណាង ភាឆ្លើយថាបងៗ និងក្មួយខ្លួននិងប្រពន្ធខ្លួន មកឈរលើផ្លូវស្រាប់តែឈ្មោះ [redacted] ភាក់ យកដុំឥដ្ឋគប់ត្រូវបងថ្លៃឈ្មោះ [redacted] សារី មួយដុំឥដ្ឋត្រូវស្មាខាងស្តាំពេលនោះកូនខ្លួនឈ្មោះ [redacted] ភាក់ បានហៅមករកពួកកូនខ្លួនផ្សេងទៀត ហើយស្រែកថា ឯងខ្លាំងវាយជាមួយអញ ហើយលឺដូចនេះ ខ្លួនក៏និយាយឯងកុំមានគំនិតអាក្រក់រួចខ្លួនប្រាប់ទៅចៅប្រុសខ្លួនឈ្មោះ [redacted] ចិត្រា ចាំកូនខ្លួនឈ្មោះ [redacted] ភាក់ ចូលក្នុងផ្ទះហើយចៅខ្លួនបានចាប់កូនប្រុស ចូលក្នុងរបងផ្ទះកូនខ្លួន ហើយទាញទ្វាររបងបិតរួចកូនប្រុសខ្លួននោះបានទាញទ្វាររបងចេញមកជេររករឿងកូនចៅខ្លួនទៀតបើបន្តិចទៅសមត្ថកិច្ចនគរបាលចុះមកអន្តរាគមន៍ទើបកូនខ្លួនឈ្មោះ [redacted] ភាក់ ដើរចូលក្នុងផ្ទះវិញរួចគេចខ្លួនបាត់បញ្ជាក់ពេលនោះខ្លួនដេកក្នុងផ្ទះទើបមិនបានដឹងថាអ្នកណាបាញ់។

៧-តាមចម្លើយសាក្សីឈ្មោះ [redacted] យឿត បានឆ្លើយថាៈ កាលពីថ្ងៃទី ១៣ ខែសីហា ឆ្នាំ ២០២០ វេលាម៉ោង ០៩យប់ពេលខ្លួនកំពុងនៅក្នុងផ្ទះស្រាប់តែលឺសំឡេងស្រែកដូចជាសំឡេងគេវាយ ដែកចេញពីទិសខាងលិចលឺដូចនេះ ក៏ដើរចេញទៅមើលដល់ផ្ទះឈ្មោះ [redacted] ភាក់ ពេលនោះឈ្មោះ [redacted] ភាក់ បានយកដំបងដេញវាយឈ្មោះ [redacted] ឡានៅមុខផ្ទះឈ្មោះ [redacted] ភា ដូចនេះឈ្មោះ [redacted] ភា បានរត់ទៅឃាត់ស្រាប់តែឈ្មោះ [redacted] ភាក់ ច្រានឈ្មោះ [redacted] ភា ដួលទៅលើដីភ្លាមនោះឈ្មោះ [redacted] កាលីន និងឈ្មោះ [redacted] ចិត្រា បានចូលទៅចាប់ចេញនិងទាញចូលទៅដីឡូត៍របស់ ខ្លួននៅទល់មុខផ្ទះរបស់ឈ្មោះ [redacted] ភា ដោយពេលនោះមិនមានអ្នកណាប្រើហិង្សាដាក់ឈ្មោះ [redacted] ភាក់ ទេពេលនោះសមត្ថកិច្ចបានមកដល់ឈ្មោះ [redacted] ភាក់ បានគេចខ្លួនបាត់។បញ្ជាក់ពេលនោះខ្លួនបានឃើញឈ្មោះ [redacted] ភាក់ ឈរកាន់ដំបងនៅមុខផ្ទះហើយពុំមាននរណាម្នាក់កាន់កាំភ្លើងដែលដូចនេះហើយច្បាស់ជាឈ្មោះ [redacted] ភាក់ យកដំបងទៅវាយទ្វាផ្ទះរបស់ឈ្មោះ [redacted] ភា។

Scanned with CamScanner

៨-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ភារ៉ា បានឆ្លើយថា: កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០២០ ម៉ោង ០៩ យប់ខ្លួន និងប្រពន្ធខ្លួនកំពុងដេកនៅផ្ទះ ក៏បានលឺគេឈ្លោះគ្នានៅមុខផ្ទះឈ្មោះ [redacted] ភា ហើយខ្លួនបានឃើញឈ្មោះ [redacted] ភាក់ ឈរកាន់ដំបងវាយជញ្ជាំងផ្ទះ [redacted] ភា លឺគ្រាំងៗហើយក៏បានឃើញឈ្មោះ សារី ហៅ រ៉ា បានចូលមកឃាត់ឈ្មោះ [redacted] ភាក់ដោយមិនបានឃើញសារីបានកាន់ អាវុធឬ វត្ថុអ្វីទេហើយក៏មិនមានការផ្ទុះអាវុធដែល ។ហើយឈ្មោះ [redacted] ភាក់ ក៏បានដើរចូលផ្ទះវិញដោយមិនមានរបួសស្នាមអ្វីដែល ។ វេលាម៉ោង ១០យប់ឈ្មោះ [redacted] ភាក់ ទូរស័ព្ទមកឲ្យយកការបូបលុយនៅមុខផ្ទះមកទុកខ្លួនក៏សួរថាពូជិះអ្វីមកឈ្មោះ [redacted] ភាក់ក៏ឆ្លើយថាពូជិះម៉ូតូមករឿងហេតុយ៉ាងណាខ្លួនមិនបានដឹងទេ។

៩-ផ្អែកតាមចម្លើយជនរងគ្រោះឈ្មោះ [redacted] សារី ,ឈ្មោះ [redacted] ភា និងសាក្សីឈ្មោះ [redacted] ភារ៉ា, ឈ្មោះ [redacted] ខាន់ , ឈ្មោះ [redacted] ង៉ែត និងឈ្មោះ [redacted] យឿត ឱ្យដឹងថាជនជាប់ចោទឈ្មោះ [redacted] ភាក់ ពិតជាបានស្ទុះទៅយកដុំឥដ្ឋប្រហោងគប់ និងយកដំបងឬស្សី ហើយនិងកាំបិតខ្មែរដេញកាប់ជនរងគ្រោះ និងធ្វើឱ្យខូតខាតផ្ទះអស់ជាច្រើនកន្លែង ពិតប្រាកដមែន។

១០-អំពើជនជាប់ចោទឈ្មោះ [redacted] ភាក់ មានចេតនាទុច្ចរិត ដែលចាត់ទុកជាបទះ ហិង្សាដោយចេតនា តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

១១-ជនជាប់ចោទឈ្មោះ [redacted] ភាក់ ជាសមត្ថជនមានស្មារតីធម្មតា អាចយល់ដឹងពីបច្ច័យ និងព្យសនកម្មដែលកើតឡើងពីអំពើរបស់ខ្លួនដែល បានប្រព្រឹត្ត។

១២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ភាក់ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណ: និងសណ្តាប់ធ្នាប់សង្គមដូចនេះត្រូវ តែទទួលខុសត្រូវចំពោះមុខច្បាប់។

១៣-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភាក់ ជាប់ចោទពីបទ: ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

**ខ-អំពីសំណងរដ្ឋប្បវេណី**

-ជនរងគ្រោះឈ្មោះ [redacted] សារី បានឆ្លើយនៅដំណាក់កាលចៅក្រមជំនុំជម្រះ សុំទាមទារជម្ងឺចិត្តចំនួន USD ៥០០០ (ប្រាំពាន់ដុល្លារអាមេរិក) និងថ្លៃមេធាវីចំនួន USD ១ ០០០០ (មួយម៉ឺនដុល្លារអាមេរិក) និងសុំផ្តន្ទាទោសជនល្មើសតាមច្បាប់ ដូច្នេះអាចឱ្យតុលាការ សម្រេចអំពីសំណាងរដ្ឋប្បវេណីបាន។

**គ-អំពីទោសះ**

**ហេតុដូច្នេះតុលាការ**

**<u>សម្រេច</u>**

១- ផ្តន្ទាទោសះ លើជនជាប់ចោទឈ្មោះ [redacted] ភាក់ (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយ:ពេល ០១ (មួយឆ្នាំ) តែទោលត្រូវព្យួរ។

ពីបទះ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ភាក់ សងសំណងជម្ងឺចិត្តចំនួន ២,០០០.០០០ រ (ពីរលានរៀល) មកដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារី និងឈ្មោះ [redacted] ភា ការទាមទារលើពីនេះត្រូវច្រាន ចោល។

Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១ កំបាំងមុខជនត្រូវចោទឈ្មោះ [redacted] ភាក់ ,កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារី និងចំពោះមុខឈ្មោះ [redacted] ភា ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]

**ជូនដំណឹង**

**ថ្ងៃទី** ២១ **ខែ**តុលា **ឆ្នាំ២០២១**

**តំណាងអយ្យការ**

[redacted]